# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**លេខៈ** ៣៧៧ គ.ជ.ប. ស.ស.រ

# សេចក្តីសម្រេច

ស្តីពី

## ការប្រកាសបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សា
## ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា អាណត្តិទី៣ ឆ្នាំ២០១៩

## គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០២ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៧/០១០ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៥/៣២៧ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៥ ស្តីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៧/១១៦៩ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការតែងតាំងអនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជំនួសអនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលបានលាឈប់
- បានឃើញសេចក្តីសម្រេចលេខ ៧៧ ស់.ស.រ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨ ស្តីពីការប្រកាសកាលបរិច្ឆេទនៃការបោះឆ្នោតលើកទី៣ ដើម្បីជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ របស់រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញសេចក្តីសម្រេចលេខ ០៤៥ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យប្រើប្រាស់បទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- បានឃើញសេចក្តីសម្រេចលេខ ០៩៨ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៩ស្តីពីការដាក់ឱ្យប្រើប្រាស់លើបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- យោងប្រតិទិននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី៣ ឆ្នាំ២០១៩
- យោងសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតលេខ ៣៧៥ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា អាណត្តិទី៣ ឆ្នាំ២០១៩
- យោងសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតលេខ ៣៧៦ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការកំណត់បែងចែកអាសនៈសម្រាប់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតតាមមណ្ឌលបោះឆ្នោត ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា អាណត្តិទី៣ ឆ្នាំ២០១៩

# សម្រេច

**ប្រការ ១.-**

ប្រកាសទទួលស្គាល់ជាផ្លូវការបេក្ខជនជាប់ឆ្នោត ជាសមាជិកក្រុមប្រឹក្សាតាមមណ្ឌលបោះឆ្នោតក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា អាណត្តិទី៣ ថ្ងៃអាទិត្យ ទី២៦ ខែឧសភា ឆ្នាំ២០១៩ ដូចមានរាយនាមក្នុងទម្រង់បែបបទលេខ១១១៨ខ និងទម្រង់បែបបទលេខ១១១៨ស ភ្ជាប់មកជាមួយ ។

**ប្រការ ២.-**

សេចក្តីសម្រេចនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ប្រការ ៣.-**

អគ្គលេខាធិការដ្ឋាន គ.ជ.ប ត្រូវផ្សព្វផ្សាយសេចក្តីសម្រេចនេះ ជាសាធារណៈឱ្យបានទូលំទូលាយ និងមានប្រសិទ្ធភាព ។

ថ្ងៃពុធ ៣រោច ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ២០១៩

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

**ស៊ិក ប៊ុនហុក**

**កន្លែងទទួល**
- រាជរដ្ឋាភិបាល
- ក្រសួងមហាផ្ទៃ
- គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត
  « ដើម្បីជូនជ្រាប »
- គជ.ខប
- បណ្ណសារដ្ឋានជាតិ
- ឯកសារ-កាលប្បវត្តិ